គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គ.ជ.ប.ជ

NATIONAL COMMITTEE FOR COUNTER TRAFFICKING (N.C.C.T)

# ក្រមសីលធម៌សម្រាប់បុគ្គលិក ដែលធ្វើការនៅមណ្ឌលចត្តាឡីស័ក ក្នុងអំឡុងពេលនៃការផ្ទុះជំងឺកូវីដ-១៩

## សារតារ

បច្ចុប្បន្ននេះ ពិភពលោកកំពុងជួបប្រទះនឹងការរាតត្បាតជាសកលនៃវីរុសក្លូណាប្រភេទថ្មី (ដែលមានឈ្មោះថា កូវីដ-១៩) នេះបើតាមការប្រកាសរបស់អង្គការសុខភាពពិភពលោក កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ កំពុងមានកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លា ដើម្បីទប់ស្កាត់ និងពន្យឺតអត្រានៃការឆ្លងនៅតាមប្រទេសនានា។ ការសាយភាយវីរុសពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈដំណក់ទឹកតូចល្អិត និងតាមរយៈការប៉ះពាល់ជាមួយនឹងផ្ទៃដែលមានវីរុស កំពុងបង្កការគំរាមកំហែងដល់សុខភាពសាធារណៈ។ ការរក្សាគម្លាតពីគ្នា និងការធ្វើចត្តាឡីស័កបុគ្គលដែលអាចប្រឈមនឹងការឆ្លងវីរុសនេះ គឺជាវិធានការមួយចំនួនក្នុងចំណោមវិធានការសំខាន់ៗ ដែលកំពុងត្រូវបានធ្វើឡើង ដើម្បីមិនឱ្យមានការឆ្លងច្រើនករណីក្នុងរយៈពេលខ្លី។

ជំងឺកូវីដ-១៩ គឺជាជំងឺឆ្លងរាតត្បាតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងជះឥទ្ធិពលខ្លាំងដល់សុខុមាលភាពរបស់មនុស្ស ក្នុងនោះដែរអំពើហិង្សាលើផ្លូវភេទ និងយេនឌ័រគឺជាហានិភ័យមួយ។ ការរឹតត្បិតការបំលាស់ទី ក៏ដូចជាការជាប់នៅក្នុងជំរុំឬកន្លែងរៀបចំដោយមានធនធានមានកំណត់ ធ្វើឱ្យហានិភ័យ និងអត្រាប្រេវ៉ាឡង់ នៃអំពើហិង្សាកាន់តែកើនឡើង។ បើនិយាយពីកិច្ចការពារកុមារវិញ មានផលប៉ះពាល់ជាសក្តានុពលធំ ៗ ចំនួន ៣ រួមមាន៖ ១) ការធ្វេសប្រហែស និងកង្វះការថែទាំពីមាតាបិតា២) សុខភាពផ្លូវចិត្តនិងការព្រួយផ្លូវចិត្តនិង ៣)ការកើនឡើងនៃការប្រឈមនឹងអំពើហិង្សា រួមមានអំពើហិង្សាផ្លូវភេទ ការរំលោភបំពានលើរាងកាយ និងអារម្មណ៍។

## វិសាលភាពនៃការអនុវត្ត

ក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើងសម្រាប់បុគ្គលជាច្រើន រួមមាន៖ អ្នកផ្តល់សេវា អ្នកការពារសន្តិសុខ អ្នកស្ម័គ្រចិត្ត និងតួអង្គទាក់ទងផ្សេងទៀតដែលមកពីស្ថាប័នពាក់ព័ន្ធនានា កំពុងដំណើរការមណ្ឌលចត្តាឡីស័ក ដែលជាវិធានការឆ្លើយតបបន្ទាន់ចំពោះវីរុសកូវីដ-១៩។ ភាគីពាក់ព័ន្ធទាំងអស់( ដូចជាអាជ្ញាធរបុគ្គលិកអ្នកស្ម័គ្រចិត្ត។ល។) នៅតាមមណ្ឌលចត្តាឡីស័កទាំងនេះមានភារកិច្ចផ្តល់ការថែទាំដល់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស ដែលរងផលប៉ះពាល់

គ្រប់វ័យ មានសាវតាចម្រុះ និងជាអ្នកទទួលខុសត្រូវ ត្រូវធានាយ៉ាងណាឱ្យអ្នកដែលកំពុងធ្វើចត្តាឡីស័កទទួលបានសេវាប្រកបដោយសីលធម៌វិជ្ជាជីវៈ និងធានាឱ្យមានការគាំពារ គោរព ការពារ សេចក្តីថ្លៃថ្នូរ ថែរក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប ទោះបីកំពុងបំពេញ ឬសំរាកពីភារកិច្ច។

# ក្រមសីលធម៌

ដើម្បីជួយដល់មនុស្សដែលកំពុង ធ្វើចត្តាឡីស័កឱ្យមានសុវត្ថិភាព និងកាត់បន្ថយការព្រួយបារម្ភ បុគ្គលិកមកពីទីភ្នាក់ងារ និងស្ថាប័នពាក់ព័ន្ធដទៃទៀតដែលកំពុងដំណើរការ ឬកំពុងចូលរួមសម្របសម្រួលសកម្មភាពចត្តា ឡីស័កក្នុងប្រទេសកម្ពុជា ត្រូវប្រកាន់ខ្ជាប់តាមគោលការណ៍ដូចខាងក្រោម៖

១. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ត្រូវយល់ថា ប្រជាជនដែលកំពុងត្រូវបានឱ្យដាក់នៅក្នុងទីកន្លែង ចត្តាឡីស័ក មិនត្រូវចាត់ទុកជាមនុស្សដែលត្រូវបានដកហូតសេរីភាពឡើយ។ ពួកគេត្រូវបានដាក់ឱ្យនៅទីនោះ ដោយអនុវត្តតាមនីតិវិធីចត្តាឡីស័ក ត្រូវការការថែទាំសុខភាព និងការគាំទ្រ ជាការប្រុងប្រយ័ត្នខាងវេជ្ជសាស្ត្រ។

២. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ ត្រូវយល់ពីវិធានការបង្ការការចម្លងរោគ យល់ពីហានិភ័យនៃវីរុស កូវីដ-១៩ និងត្រូវទទួលបានការបណ្តុះបណ្តាល ព្រមទាំងទទួលបានការពិនិត្យតាមដានក្នុងការអនុវត្ត វិធានការការពារខ្លួន។

៣. បុគ្គលិកនិងអ្នកផ្តល់សេវាទាំងអស់ត្រូវយល់ពីភាពខុសគ្នានៃយេនឌ័រ គោលគំនិតសំខាន់ៗ ដែលទាក់ទងនឹងអំពើហិង្សាផ្លូវភេទនិងយេនឌ័រ និងសេវាកម្មបញ្ជូនដែលចាំបាច់សម្រាប់ជនរងគ្រោះ។

៤. បុគ្គលិកនិងអ្នកផ្តល់សេវាទាំងអស់ត្រូវគិតពិចារណាពីស្ថានភាពនិងភាពងាយរងគ្រោះជាក់លាក់របស់កុមារ។ ពេលខ្លះកុមារប្រហែលមិនដឹង ឬមិនយល់ពីការរឹតត្បិតលើការធ្វើបំលាស់ទី។ ពួកគេអាចរស់នៅឬធ្វើការនៅតាមផ្លូវ អាចគ្មានឪពុកម្តាយ ឬក្រុម

គ្រួសារថៃទាំ។ ពួកគេអាចទទួលរងនូវអំពើហិង្សា និងការរំលោភបំពាននៅផ្ទះ ដូច្នេះត្រូវបង្ខំឱ្យស្វែងរកសុវត្ថិភាពនៅកន្លែងផ្សេងទៀត។

៥. បុគ្គលិកទាំងអស់ ជាពិសេសអ្នកផ្តល់សេវា ដូចជា អ្នកគ្រប់គ្រង អ្នកផ្តល់សេវាសង្គម និងអ្នកផ្តល់សេវាសុខភាព ត្រូវធានាឱ្យមានការផ្តល់ជំនួយ តាមបែបផែនដែលមានសុវត្ថិភាព ផ្តល់ការគោរព សេចក្តីថ្លៃថ្នូរ និងភាព ងាយស្រួលក្នុងការទទួលបានសេវាស្មើភាពគ្នា រវាងស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសស្របតាមវ័យ សមត្ថភាព ជាតិពន្ធុ សាសនា ការអប់រំ ស្ថានភាពសេដ្ឋកិច្ច និន្នាការផ្លូវភេទ សញ្ជាតិ ស្ថានភាពចំណាកស្រុក អត្តសញ្ញាណយេនឌ័រ និងសារៈតាចម្រុះផ្សេងទៀតខុសៗគ្នា។ ការផ្តល់សេវានេះរួមមានការផ្តល់ព័ត៌មានដែលចាំបាច់ ដូចជា នីតិវិធីនៃយន្តការពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ សុខភាព អាហារូបត្ថម្ភ អនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួន ការផ្សព្វផ្សាយព័ត៌មាន ការឆ្លើយតបលើអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ករណីកិច្ចការពារកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ និងការប្រមូលនិងផ្តល់ទិន្នន័យដែលបានបែងចែកអាយុនិងភេទ។ ព័ត៌មានទាំងនេះគួរតែត្រូវបានផ្តល់ឱ្យ ដោយគោរពតាមគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិការស្តង់ដារដែលផ្តល់ឱ្យពួកគេនូវភាពជាម្ចាស់ និងការទទួលខុសត្រូវ។

៦. ប្រសិនបើមានកុមារដែលបំបែកពីគ្រួសារ ឬមិនមានឪពុកម្តាយ ឬគ្មានអ្នកមើលថៃ បុគ្គលិក និងអ្នកផ្តល់សេវាគួរតែធានាថា កុមារមានសិទ្ធិទទួលបានការគាំទ្រនិងជំនួយពីអ្នកផ្តល់សេវាសង្គម ដូចជាការជួបជុំជាមួយក្រុមគ្រួសារវិញជាដើម។ បុគ្គលិក និងអ្នកផ្តល់សេវា គួរតែជូនដំណឹងពីករណីនៃកុមារដែលបែកបាក់ ឬមិនមានឪពុកម្តាយឬគ្មានការមើលថៃពីឪពុកម្តាយទៅកាន់មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ដែលជាជនបង្គោលសម្រាប់ករណីទាំងអស់នោះ។

៧. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ គួរប្រើប្រាស់ការអប់រំបែបចិត្តសាស្ត្រ/ការបញ្ជ្រាបការយល់ដឹង និងការពង្រឹងជាវិជ្ជមានសម្រាប់ការផ្លាស់ប្តូរអាកប្បកិរិយា។ អំពើហិង្សាគ្រប់រូបភាព ដែលរួមមានការវាយដំ ទះ ឬប្រើទំរង់ផ្សេងទៀតនៃការរំលោភបំពាន ឬការយាយីផ្លូវចិត្តរបស់អ្នកដែលបានដាក់នៅក្នុងទីចត្តាឡីស័កត្រូវហាមឃាត់។

៨. ការកេងប្រវ័ញ្ចផ្លូវភេទ និងរាល់ការរំលោភបំពានគ្រប់ទម្រង់និងគ្រប់រូបភាពទាំងអស់ទៅលើបុគ្គលណាម្នាក់នៅទីចត្តាឡីស័កត្រូវបានហាមឃាត់ដាច់ខាត និងជាទង្វើខុសច្បាប់។ បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ មិនគួរស្នើសុំ ឬទទួលយកសាគុណផ្ទាល់ខ្លួន ជាថ្នូរនឹងការអនុញ្ញាតឱ្យអ្នកណាម្នាក់ ចូលរួមក្នុងសកម្មភាព និង/ ឬទទួលបានសេវាក្នុងមណ្ឌលចត្តាឡីស័កនោះឡើយ។ ការផ្លាស់ប្តូរជាទឹកប្រាក់ការងារទំនិញអត្ថប្រយោជន៍ ឬសេវាកម្មផ្លូវភេទរួមទាំងការអនុគ្រោះខាងផ្លូវភេទ ឬទម្រង់នៃការធ្វើឱ្យមានភាពអាម៉ាស ការបាត់បង់កិត្តិយស ឬកេងប្រវ័ញ្ច ត្រូវបានហាមឃាត់។

៩. មិនត្រូវធ្វើការលេបខាយផ្លូវភេទ ទៅដល់បុគ្គលណាម្នាក់ ដែលកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័កនោះឡើយ។ សកម្មភាពផ្លូវភេទជាមួយកុមារ(ជនមានអាយុក្រោម ១៨ឆ្នាំ) ត្រូវបានហាមឃាត់ដោយច្បាប់ដោយមិនគិតពីអាយុភាគច្រើន ឬអាយុនៃការយល់ព្រម។ ជំនឿខុសទាក់ទងនឹងអាយុរបស់កុមារមិនអាច ជាលេសយកមកការពារនោះទេ។

១០. ក្នុងករណីដែលបុគ្គលិកមានការព្រួយបារម្ភ ឬមានការសង្ស័យពាក់ព័ន្ធនឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទ ឬការរំលោភបំពានក្នុងទម្រង់ផ្សេងទៀត ដែលអាចប្រព្រឹត្តដោយបុគ្គលណាម្នាក់ បុគ្គលិកនោះគួររាយការណ៍ពីការព្រួយបារម្ភនេះតាមរយៈយន្តការរាយការណ៍ (ចាត់តាំងអ្នកគ្រប់គ្រងម្នាក់ ឬអ្នកសម្របសម្រួលម្នាក់នៅក្នុងកន្លែងចត្តាឡីស័ក ដើម្បីទទួលបន្ទុកទទួលការរាយការណ៍ពីអំពើហិង្សាការរំលោភបំពាន និងការបៀតបៀតផ្លូវភេទ)។ បុគ្គលិកត្រូវបញ្ជូនជនរងគ្រោះទៅសេវាថែទាំសុខភាព និងសេវាកម្មសង្គមឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ព្រោះការព្យាបាល ឬការថែទាំមួយចំនួនត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់។ចំពោះករណីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រគួរតែត្រូវបានបញ្ជូនទៅជនបង្គោលទទួលខុសត្រូវតាមខេត្ត នៅមន្ទីរកិច្ចការនារីដើម្បីគ្រប់គ្រងករណី។ ចំពោះករណីរបស់កុមារ គួរតែត្រូវបានរាយការណ៍ទៅបុគ្គលិកសង្គមកិច្ច និងជនបង្គោលថ្នាក់ខេត្តសម្រាប់សុខុមាលភាពកុមារនៅមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងករណី។

១១. ត្រូវសម្របសម្រួលជាមួយអ្នកផ្ដល់សេវាជួរមុខផ្សេងទៀត (សេវាសុខភាព / សង្គម)និងធ្វើតាមនីតិវិធីដែលមានស្រាប់សម្រាប់ការបញ្ជូន នៅតាមកន្លែងចត្តាឡីស័ក ប្រសិនបើស្ត្រី ឬកុមារត្រូវបានរកឃើញថាមានការថប់អារម្មណ៍។ ផលប៉ះពាល់បន្ទាប់បន្សំនៃវីរុសកូវីដ-១៩ ដែលមានសក្តានុពលទាក់ទងនឹងការការពារកុមាររួមមានសុខភាពផ្លូវចិត្តនិងបញ្ហាផ្លូវចិត្ត និងការកើនឡើងនូវអំពើហិង្សា។ បុគ្គលិកនៅក្នុងកន្លែងចត្តាឡីស័កមានតួនាទីសំខាន់ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលត្រូវការជំនួយផ្នែកសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្ររួមទាំងជនរងគ្រោះនៃការរំលោភបំពាន។ អាចរកអ្នកប្រឹក្សាយោបល់បានចាប់ពីម៉ោង៨ព្រឹក ដល់ម៉ោង១០យប់ ៧ថ្ងៃក្នុងមួយសប្តាហ៍តាមរយៈខ្សែទូរស័ព្ទចំនួន ៣ដូច ខាងក្រោម៖

**ក. ០១៧ ២២២ ៣៧២**

**ខ. ០៨៩ ៦៦៦ ៣២៥**

**គ. ០៩៧ ៩១១១ ៩១៨**

១២. អ្នកគ្រប់គ្រងនៅគ្រប់កម្រិតទាំងអស់ត្រូវមានការទទួលខុសត្រូវខ្ពស់ដើម្បីធានាការអនុវត្តតាមក្រមសីលធម៌នេះក៏ដូចជាផ្ដល់ការគាំទ្រ និងបង្កើតនូវប្រព័ន្ធដែលរក្សាបាននូវបរិយាកាសអនុវត្តក្រមសីលធម៌នេះ។

១៣. ត្រូវចងក្រងជាឯកសារនិងរក្សាទុកដោយសុវត្ថិភាពនិងធានាការសម្ងាត់សម្រាប់ព័ត៌មានស្តីពីការគ្រប់គ្រងករណី។

ការបំពានក្រមសីលធម៌នេះ នឹងត្រូវចាត់ទុកថា ការប្រព្រឹត្តមិនត្រឹមត្រូវ និងត្រូវបានស៊ើបអង្កេតដើម្បីចាត់ការតាមផ្លូវច្បាប់។

សហការជាមួយ៖

ក្រសួងសុខាភិបាល

គាំទ្រដោយ៖

USAID
FROM THE AMERICAN PEOPLE

unicef
for every child

UN WOMEN

UNFPA

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

Save the Children